ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២៥/២០ - ហ្គោថុន ត្រាវែល សឹវីស
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ ទូន ស៊ីផាន់
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ហ្គោថុន ត្រាវែល សឹវីស**
អាសយដ្ឋាន ៖ ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០១២ ៤៣៨ ៩៩២ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ ៖

| | |
|---|---|
| ១- លោកស្រី Chang Shuling | ប្រធានក្រុមហ៊ុន |
| ២- លោកស្រី ស៊ីន ស៊ីនួន | អ្នកបកប្រែ |
| ៣- លោកស្រី អ៊ឹង ផារី | គណនេយ្យ |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោ ថុន ត្រាវែល សឹវីស**
អាសយដ្ឋាន ៖ ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០៨៩ ២៨ ៨២ ៩៦/០៩២ ៥១ ៩៨ ២៧ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

| | |
|---|---|
| ១- លោក ព្រិត សុអួត | មន្ត្រីច្បាប់ ACIL |
| ២- លោក ប៉ាង ណារុំ | ប្រធានសហជីពមូលដ្ឋាន |
| ៣- លោក ជួន វ៉ាឌី | អនុប្រធានសហជីពមូលដ្ឋាន |
| ៤- លោក សួន ជឿម | សមាជិកសហជីពមូលដ្ឋាន |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីខាងកម្មករនិយោជិត នៅតែប្រកាន់ជំហរទាមទារដដែល គឺទាមទារក្រុមហ៊ុនទូទាត់ប្រាក់បំណាច់កិច្ចសន្យាការងារកម្មករនិយោជិតឈ្មោះ ចាន់ ធា និងឈ្មោះ សួន ជឿម តាមច្បាប់ស្តីពីការងារ រួមមានៈ ប្រាក់ជូនដំណឹងមុន ប្រាក់បំណាច់បណ្តេញចេញ ប្រាក់សោហ៊ុយជំងឺចិត្ត ប្រាក់ខែចុងក្រោយ ប្រាក់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំ និងឈប់សម្រាកថ្ងៃបុណ្យជាតិ។ ភាគីខាងនិយោជក ក្រុមហ៊ុនអាចទូទាត់ប្រាក់បំណាច់កិច្ចសន្យាការងារ ឈ្មោះ ចាន់ ធា និងឈ្មោះ សួន ជឿម រួមមានប្រាក់ជូនដំណឹងមុន ប្រាក់រំលឹកអតីតភាពការងារ និងប្រាក់ខែចុងក្រោយ រីឯប្រាក់សោហ៊ុយជំងឺចិត្ត ប្រាក់ឈប់សម្រាកប្រចាំឆ្នាំ និងប្រាក់សម្រាកថ្ងៃបុណ្យមានប្រាក់ឈ្នួល ក្រុមហ៊ុនមិនអាចទូទាត់ជូនបានទេ ដោយកន្លងមក ក្រុមហ៊ុនបានបើកប្រាក់ឈ្នួលជូនកម្មកររាល់ខែ រីឯភាគីកម្មករនិយោជិតបើកប្រាក់ឈ្នួលរួច មិនបានបំពេញការងារអោយក្រុមហ៊ុនទេ ដោយមិនមានភ្ញៀវដឹក។

២- ភាគីខាងកម្មករនិយោជិត ទាមទារក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលរៀងរាល់ខែ ដោយគ្មានការព្យួរ និងទៀងទាត់ពេលវេលា ឬទូទាត់ផ្តាច់កិច្ចសន្យាការងារអោយពួកខ្ញុំជាកម្មករនិយោជិតចំនួន ១២នាក់ ដែលនៅសល់ពីព្រោះក្រុមហ៊ុនបានលក់ឡានអស់ហើយ ពុំមានឡានអោយពួកខ្ញុំបំពេញការងារទៀតទេ។ ភាគីខាងនិយោជកថា ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត គឺដោយសារសេដ្ឋកិច្ចធ្លាក់ចុះ និងគ្មានភ្ញៀវ ក្រុមហ៊ុនសុំបញ្ជាក់ការលក់ឡាន គឺលក់តែឡានចាស់ៗទេ ហើយក្រុមហ៊ុននៅមានឡានអាចបំរើសេវាកម្មចំនួនប្រាំបីគ្រឿង។ ភាគីខាងកម្មករនិយោជិត សូមបដិសេធការលើកឡើងរបស់ភាគីនិយោជកថា មានឡានអាចបំរើសេវាកម្ម ចំនួនប្រាំបីគ្រឿង។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គោ ថូន ត្រាវែល ស៊ីវីស លេខ ០២៦ ម.ក.ប ចុះថ្ងៃចន្ទ ៦កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

បញ្ញានីតិវិធី ៖

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស ស្នើសុំឱ្យជួយដោះស្រាយវិវាទការងាររួមរបស់សហជីព។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ក៏បានអញ្ជើញភាគីទាំងពីរមកចូលរួមដោះស្រាយវិវាទការងាររួម ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចវិវាទដែលមិនសះជាចំនួន ២ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាលនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស លេខ ០២៦ ម.ក.ប ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ២ចំណុចនេះ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ២ រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ២ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១ចំណុច គឺចំណុចវិវាទទី១។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់ចំនួន ១ចំណុច តែប៉ុណ្ណោះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០២០។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង ការរកឃើញនៃអង្គហេតុ និងអង្គច្បាប់ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីសំណើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេលពីរខែ។

ARBITRATION COUNCIL

២- លិខិតលេខ ០០៦ មកប ចុះថ្ងៃព្រហស្បតិ៍ ៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ជម្រាបមក លោកស្រីនាយិកាក្រុមហ៊ុន ហ្គោថ្វូន ត្រាវែល ស៊ីវីស ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតចាត់តាំងរបស់មជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ គោរពជូនប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីចាត់តាំងឈ្មោះ ព្រិត សុអ៊ួត មន្ត្រីច្បាប់ចូលរួមដោះស្រាយសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល នាថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ ចុះថ្ងៃព្រហស្បតិ៍ ១ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០។

២- ពាក្យសុំជួយដោះស្រាយ និងផ្ទេរសិទ្ធិ ចុះថ្ងៃអង្គារ ១៤ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ របស់ឈ្មោះ ប៉ាង ណារុំ ជាប្រធានសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថ្វូន ត្រាវែល ស៊ីវីស គោរពជូន លោក វីលសៀម ខន់គ្លីន នាយកនៃមជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ ស្តីពីស្នើសុំលោក ព្រឹត សុអ៊ួត មន្ត្រីច្បាប់នៃមជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ ជួយដោះស្រាយវិវាទការងាររួម និងផ្ទេរសិទ្ធិជូនលោក ព្រឹត សុអ៊ួត ក្នុងការចូលរួមគ្រប់ដំណើរការនីតិវិធីនៃការដោះស្រាយវិវាទការងាររួមរបស់សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថ្វូន ត្រាវែល ស៊ីវីស នៅក្នុងសវនាការ (សំណុំរឿងលេខ ០២៥/២០) ក្រុមប្រឹក្សាអាជ្ញាណ្តាល។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៦៨ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។

៤- លិខិតលេខ ០០៨ មកប ចុះថ្ងៃសុក្រ ១១ រោច ខែភទ្របទ ឆ្នាំចរ សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថាសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថ្វូន ត្រាវែល ស៊ីវីស ជាអង្គការវិជ្ជាជីវៈមួយ បានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៥- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថ្វូន ត្រាវែល ស៊ីវីស លេខ ០០៨ មកប ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។

៦- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថ្វូន ត្រាវែល ស៊ីវីស លេខ ៣៩០/១៩ កប/វបវក ចុះថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

៧- លិខិតលេខ ០០១/២០ ស.ប.ក.ហ្គ ចុះថ្ងៃចន្ទ ៩កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោ

ARBITRATION COUNCIL

ថូន ត្រាវែល សឺវីស គោរពជូន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីស្នើជួយដោះស្រាយវិវាទការងាររួម រវាងសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស។

៨- លិខិតអញ្ជើញលេខ ០៥៧ ម.ក.ប ចុះថ្ងៃសុក្រ ១២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប អញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្សះផ្សាវិវាទការងារ។

៩- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០។

១០- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។

១១- លិខិតចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស ស្តីពីសូមជូនដំណឹងទៅលោក សួន ជឿម។

១២- លិខិតទូទាត់ផ្តាច់កិច្ចសន្យា ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០។

១៣- លិខិតចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់នាយកក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីការជូនដំណឹងស្តីពីការផ្តាច់កិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២នាក់។

១៤- កំណត់ហេតុចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ របស់ឈ្មោះ ប៉ាង ណារុំ, ជួន រ៉ាឌី, ចាន់ សុភា, ហោ សេងអ៊ី, សំ សីហា, រ៉ូ វន, យុត ម៉ៅ, ឆាយ ឧត្តម, ញ៉ឹក នាង, អ៊ូម សិទ្ធិ, ចាន់ ដារ៉ា, ថោង វីណា, និង សួន ជឿម។

១៥- លិខិតលេខ ០០៤/២០ ស.ប.ក.ហ្គ ចុះថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ របស់សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស គោរពជូន លោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនសារណានៃក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស។

១៦- ឯកសារជារូបភាព។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្គោ ថូន ត្រាវែល សឺវីស លេខ ០២៦ ម.ក.ប ចុះថ្ងៃចន្ទ ៦កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ្គោ ថូន ត្រាវែល សឺវីស ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។

THE ARBITRATION COUNCIL

៣- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតចុះបញ្ជីកាអង្គការវិជ្ជាជីវៈសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស លេខ ៣៩០/១៩ ក.ប/វ.ប.រ.គ ចុះថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៦៧ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៦៨ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស គឺជាក្រុមហ៊ុនមានសកម្មភាពចម្បងផ្នែកសេវាកម្មដឹកជញ្ជូនភ្ញៀវទេសចរណ៍ និងមានជួលកម្មករនិយោជិតសរុបចំនួន ២១(ម្ភៃមួយ)នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស ខេត្តសៀមរាប)*។
- គិតត្រឹមថ្ងៃសវនាការ ក្រុមហ៊ុននៅសល់កម្មករនិយោជិតចំនួន ១៩ (ដប់ប្រាំបួន) នាក់ ដោយឡែកកម្មករនិយោជិត ចំនួន ២ (ពីរ) នាក់ (ឈ្មោះ ចាន់ ធា និងឈ្មោះ ហោ សេងអ៊ី) បានព្រមទទួលយកការទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាពីនិយោជករួចហើយ។
- នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានចេញលិខិតដែលមានកម្មវត្ថុស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ដោយបានអនុញ្ញាតឱ្យនាយិកាក្រុមហ៊ុនអនុវត្តការព្យួរកិច្ចសន្យាការងារឱ្យបានត្រឹមត្រូវតាមច្បាប់។ សុពលភាពនៃការព្យួរកិច្ចសន្យានេះ គឺចាប់ពីថ្ងៃទី១ ខែមីនា រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។

ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលរៀងរាល់ខែ និងទៀងទាត់ពេលវេលា ដោយគ្មានការព្យួរកិច្ចសន្យាការងារ ឬទូទាត់ប្រាក់ផ្តាច់កិច្ចសន្យាការងារឱ្យកម្មករនិយោជិតចំនួន ១១ (ដប់មួយ) នាក់

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកទូទាត់ប្រាក់ឈ្នួលសម្រាប់ខែមីនា និងខែមេសា ឆ្នាំ២០២០ ជូនកម្មករនិយោជិតដែលនៅសល់ចំនួន ១១ (ដប់មួយ) នាក់។

តារាងបញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទារ

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | ប៉ាង ណារុំ | បើកបររថយន្ត |
| ២ | ជួន រ៉ាឌី | បើកបររថយន្ត |

| | | |
|---|---|---|
| ៣ | ចាន់ សុភា | បើកបររថយន្ត |
| ៤ | សំ សីហា | បើកបររថយន្ត |
| ៥ | វ៉ូ វន | បើកបររថយន្ត |
| ៦ | ឃុត ម៉ៅ | បើកបររថយន្ត |
| ៧ | ឆាយ ឧត្តម | បើកបររថយន្ត |
| ៨ | ញ៉ឹក នាង | បើកបររថយន្ត |
| ៩ | អ៊ូម សុទ្ធិ | បើកបររថយន្ត |
| ១០ | ចាន់ ដាក់ | បើកបររថយន្ត |
| ១១ | ថោង រីណា | បើកបររថយន្ត |

- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - នៅថ្ងៃទី២៥ និងទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ និយោជកបានប្រកាសប្រាប់កម្មករនិយោជិតស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារសម្រាប់ខែមីនា និងខែមេសា ឆ្នាំ២០២០ ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប។
    - នៅថ្ងៃផ្សះផ្សាវិវាទការងាររួមនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប មន្ទីរបានប្រាប់ថា មូលហេតុដែលអធិការការងារមិនបានចុះទៅត្រួតពិនិត្យអំពីស្ថានភាពក្រុមហ៊ុនមុននឹងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ គឺដោយសារមានក្រុមហ៊ុនផ្នែកទេសចរណ៍ជាច្រើនបានដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារដែលមានស្ថានភាពដូចៗគ្នា ហើយមន្ទីរមិនមានមន្ត្រីគ្រប់គ្រាន់ដើម្បីចុះត្រួតពិនិត្យ។
    - បន្ទាប់ពីមន្ទីរអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ និយោជកបានប្រាប់ទៅតំណាងកម្មករនិយោ-ជិតរួចហើយ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសម្រាប់ខែមីនា និងខែមេសា ឆ្នាំ២០២០ គឺខុសនីតិវិធីដោយហេតុថា ៖
    - និយោជកមិនបានហៅតំណាងកម្មករនិយោជិតទៅជជែកគ្នាអំពីការព្យួរកិច្ចសន្យាការងារនេះទេ មុនពេលនិយោជកដាក់ពាក្យស្នើសុំព្យួរកិច្ចសន្យាការងារទៅមន្ទីរការងារ។
    - អធិការការងារមិនបានចុះមកជួបតំណាងកម្មករនិយោជិត ដើម្បីសួរនាំអំពីផលប៉ះពាល់ដល់កម្មករនិយោជិតពីការព្យួរកិច្ចសន្យាការងារនេះឡើយ។
    - និយោជកមិនមានហេតុផលតាមផ្លូវច្បាប់ ដើម្បីព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតនោះទេ ហើយក្រុមហ៊ុនក៏ពុំមានផលប៉ះពាល់អ្វីធំដុំដែរ។
    - ការព្យួរកិច្ចសន្យាការងារនេះគ្មានសុពលភាពនោះទេ បើនិយោជកមិនបានបង្ហាញឯកសារដែលបញ្ជាក់ថា មន្ទីរបានអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារដល់កម្មករនិយោជិត។
- ភាគីនិយោជកបានអះអាងថា ខ្លួនមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយហេតុថា ៖

- ចាប់ពីចុងខែមករា ឆ្នាំ២០២០ មក ប្រាក់ចំណូលរបស់ក្រុមហ៊ុន គឺគ្មានទេ ព្រោះគ្មានភ្ញៀវមកជួលសេវា ហេតុនេះហើយ ទើបនិយោជកសម្រេចស្នើសុំព្យួរកិច្ចសន្យាការងារទៅមន្ទីរការងារ។
- និយោជកបានដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារលើកទីមួយ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ សម្រាប់ការព្យួរខែមីនា និងខែមេសា ឆ្នាំ២០២០ ចំនួន ១៩ (ដប់ប្រាំបួន) នាក់ ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប និងលើកទីពីរ សុំព្យួរ ចំនួន ១៩ (ដប់ប្រាំបួន) នាក់ដដែល សម្រាប់ខែឧសភា និងខែមិថុនា ឆ្នាំ២០២០ មន្ទីរការងារខេត្តបានប្រាប់ថា ឱ្យក្រុមហ៊ុនដាក់ពាក្យសុំព្យួរតាមអនឡាញ។
- បន្ទាប់ពីក្រុមហ៊ុនបានដាក់ពាក្យសុំព្យួរលើកទីមួយ ក្រុមហ៊ុនមិនបានទទួលព័ត៌មានអំពីការជួយឧបត្ថម្ភប្រាក់ពីរាជរដ្ឋាភិបាលទេ។ ប៉ុន្តែ បន្ទាប់ពីបានដាក់ពាក្យសុំព្យួរលើកទីពីរ ក្រុមហ៊ុនបានទទួលព័ត៌មានអំពីការជួយឧបត្ថម្ភចំនួន ៤០(សែសិប) ដុល្លារ ក្នុងមួយខែ ហើយបានប្រាប់បុគ្គលិកថា ឱ្យផ្តិតមេដៃដើម្បីបានទទួលប្រាក់នេះពីរាជរដ្ឋាភិបាលសម្រាប់ខែឧសភា ឆ្នាំ២០២០។ ពេលនោះមានបុគ្គលិកខ្លះបានផ្តិតមេដៃ ហើយមានសមាជិកសហជីពចំនួន ១២ (ដប់ពីរ)នាក់ មិនបានផ្តិតមេដៃទេ។ នៅក្នុងការព្យួរលើកទីពីរនេះ និយោជកបានផ្ញើបញ្ជីឈ្មោះទៅមន្ទីរការងារខេត្តសៀមរាប តែបុគ្គលិកណាដែលបានផ្តិតមេដៃតាមនិយោជកប្រាប់តែប៉ុណ្ណោះ។

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកទូទាត់ប្រាក់ឈ្នួលសម្រាប់ខែមីនា និងខែមេសា ឆ្នាំ២០២០ ជូនកម្មករនិយោជិត ចំនួន ១១នាក់**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ចាប់ពីថ្ងៃទី១ ខែមីនា រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ បានធ្វើឡើងត្រឹមត្រូវតាមនីតិវិធីដែរ ឬទេ?

កថាខណ្ឌទី ១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"ពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសំភារៈធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពសហគ្រាសមិនលើសពី ពីរខែ។ ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ"។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ *៥៨/០៧-៨ ស្តារ ស្គុតវែរ* ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ បានបកស្រាយកថាខណ្ឌទី ១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារ ខាងលើថា ៖ *"ការលំបាកផ្នែកសំភារៈ ឬសេដ្ឋកិច្ចធ្ងន់ធ្ងរនេះ ជាហេតុផលដែលអាចអនុញ្ញាតឱ្យនិយោជកអាចព្យួរកិច្ចសន្យាការងារ ប្រសិនបើនិយោជកបំពេញលក្ខខណ្ឌ ២ យ៉ាងគឺ ៖*

*- ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការកិច្ចការងារ និង*

*- ការព្យួរកិច្ចសន្យាការងារនេះមិនត្រូវឱ្យលើសពី ២ ខែ។"*

លើសពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ០៨/០៧-ស៊ាវ គិញ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២ បានបកស្រាយកថាខណ្ឌទី១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារថា ៖ *"ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ គឺមានន័យថា និយោជកត្រូវគោរពតាមកាតព្វកិច្ចនៃការជូនដំណឹង និងទទួលបានការអនុញ្ញាតជាមុនពីអធិការការងារ ទើបអាចព្យួរកិច្ចសន្យាការងារដោយស្របច្បាប់បាន។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២២/០៥-អូសេអង់ ហេតុផលនៃចំណុច*

*វិវាទទី២, លេខ ៧២/០៥-ណាត ហ្គេអឹជី ហេតុផលនៃចំណុចវិវាទទី១, លេខ ១៩៨/១៣-ស៊ូ អ៊ីកែរីល (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី២, លេខ ១៦០/១៤-អូសេអង់ ហ្គាមិន ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១, លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របចំពោះការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើ ដោយយល់ថា និយោជកអាចព្យួរកិច្ចសន្យាការងារក្រោមហេតុផលនៃការលំបាកផ្នែកសម្ភារៈ ឬ សេដ្ឋកិច្ចធ្ងន់ធ្ងរបាន លុះត្រាតែការព្យួរកិច្ចសន្យាការងារ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការកិច្ចការងារ តាមរយៈការទទួលបានការអនុញ្ញាតពីអធិការការងារជាមុន។

បន្ថែមពីនេះ កថាខណ្ឌទី១ មាត្រា៧២ នៃច្បាប់ស្តីពីការងារដដែល ចែងថា ៖ *"ការព្យួរកិច្ចសន្យាការងារនាំឱ្យប៉ះពាល់តែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត"។*

ផ្អែកតាមកថាខណ្ឌទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារខាងលើ និយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតទេ នៅពេលព្យួរកិច្ចសន្យាការងារ ប៉ុន្តែកថាខណ្ឌទី១ នៃមាត្រា ៧២ ខាងលើ ត្រូវបានអនុវត្តនៅពេលដែលការព្យួរកិច្ចសន្យាការងារធ្វើឡើងដោយស្របតាមនីតិវិធីច្បាប់តែប៉ុណ្ណោះ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ៖ *"ប្រសិនបើក្រុមហ៊ុនបានធ្វើបែបបទព្យួរកិច្ចសន្យាការងារត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ដោយការព្យួរកិច្ចសន្យាការងារ ត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យពីអធិការកិច្ចការងារ នោះក្រុមហ៊ុនមិនមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតឡើយ។ ប៉ុន្តែ ប្រសិនបើក្រុមហ៊ុនមិនបានគោរពតាមច្បាប់ស្តីពីការងារ នៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ដូចបានរៀបរាប់ខាងលើទេនោះ ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ១០០ភាគរយ ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗដល់កម្មករនិយោជិត ទោះបីជាក្រុមហ៊ុនពុំមានការងារឱ្យកម្មករនិយោជិតធ្វើក៏ដោយ។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២១/០៣-ឡយ អ័ល ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៨, លេខ ០១/០៤-ញូវ កាញ់ ហេតុផលនៃចំណុចវិវាទទី១, លេខ ៦០/០៦-ញូវមេក ហ្គាមេន ហេតុផលនៃចំណុចវិវាទទី២, លេខ ៧៤/០៧-ក្លូបលអាប៉ារ៉ែល ហេតុផលនៃចំណុចវិវាទទី១, លេខ ២៧/០៨-អាក យីត ហេតុផលនៃចំណុចវិវាទទី៦, លេខ ១០៩/០៩-យូ អេស អេ ហេតុផលនៃចំណុចវិវាទទី៤, លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី ចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របចំពោះការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើផងដែរ។

នៅថ្ងៃកំណត់ដាក់ឯកសារភស្តុតាង ភាគីកម្មករនិយោជិតបានដាក់ជូនសារណាបកស្រាយចំពោះចំណុចដែលបានទាមទារមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ បន្ទាប់ពីបានពិនិត្យមើលសារណាដែលដាក់ជូននេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលកឃើញថា ខ្លឹមសារដែលបានលើកឡើងនៅក្នុងសារណា គឺបដិសេធមិនទទួលស្គាល់អង្គហេតុដែលភាគីកម្មករនិយោជិតបានទទួលស្គាល់នៅក្នុងសវនាការនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០ ទាក់ទងនឹងការជូនដំណឹងស្តីពីការដាក់ពាក្យស្នើសុំព្យួរកិច្ចសន្យាការងារ ហេតុផលដែលមន្ទីរបានប្រាប់ចំពោះការអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ និងការជូនដំណឹងដល់កម្មករនិយោជិតពីការអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ។

យោងតាមប្រការ២៥ នៃប្រកាស ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចែងថា ៖ *"ក្រុមអាជ្ញាកណ្តាលត្រូវមានសេរីភាពក្នុងការកំណត់អំពីភាពដែលអាចទទួលយកបាន ភាពពាក់ព័ន្ធ ភាពសំខាន់ និង ទំងន់នៃភស្តុតាង និងមានសេរីភាពក្នុងការកំណត់ឱ្យភាគីណាមួយ លើកភស្តុតាងមកបញ្ជាក់ទៀតផង។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ២៦៧/១៣-អេស៊ា ជុងរុន អ៊ីមផត អិចផត បានបកស្រាយខ្លឹមសារនៃប្រការ២៥ នៃប្រកាសលេខ ៩៩ សកបយ ខាងលើដោយបញ្ជាក់យ៉ាងច្បាស់ថា *"ភាពដែលអាចទទួលយកបាននៃភស្តុតាង ការកំណត់នូវភស្តុតាងដែលមានភាពសំខាន់ ទម្ងន់នៃភស្តុតាង ឬភស្តុតាងដែលពាក់ព័ន្ធនឹងសំណុំរឿង គឺជាអំណាចរបស់ក្រុមអាជ្ញាកណ្តាល។"* ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របចំពោះការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើផងដែរ។ ដោយខ្លឹមសារដែលបានលើកឡើងនៅក្នុងសារណារបស់ភាគីកម្មករនិយោជិត បានបដិសេធមិនទទួលស្គាល់អង្គហេតុដែលភាគីកម្មករនិយោជិតបានទទួលស្គាល់នៅក្នុងសវនាការនាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធមិនពិចារណា ចំពោះសារណានេះ។

យោងតាមអង្គហេតុ ភាគីទាំងពីរទទួលស្គាល់ថា នៅថ្ងៃទី២៥ និងទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ និយោជកបានប្រកាសប្រាប់កម្មករនិយោជិតពីការស្នើសុំព្យួរកិច្ចសន្យាការងារសម្រាប់ខែមីនា និងខែមេសា ឆ្នាំ២០២០ ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប។ ម៉្យាងទៀត យោងតាមឯកសារដែលភាគីនិយោជកបានដាក់ជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានចេញលិខិតចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ អនុញ្ញាតឱ្យនិយោជកព្យួរកិច្ចសន្យាការងារតាមការស្នើសុំ ដែលមានសុពលភាពចាប់ពីថ្ងៃទី១ ខែមីនា ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។ ហេតុនេះ យោងតាមកថាខណ្ឌទី ១១ នៃមាត្រា ៧១ និងកថាខណ្ឌទី១ នៃមាត្រា ៧២ និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះយល់ឃើញថា ការព្យួរកិច្ចសន្យាការងារនេះ គឺបានធ្វើឡើងស្របតាមនីតិវិធីនៃច្បាប់ស្តីពីការងារ ដែលការព្យួរកិច្ចសន្យាការងារនេះមានរយៈពេលមិនលើសពីពីរខែ ដោយនិយោជកបានជូនដំណឹង និងស្នើសុំព្យួរកិច្ចសន្យាការងារមុនពេលអនុវត្តការព្យួរកិច្ចសន្យាការងារ និងបានទទួលលិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ។

ដូច្នេះ និយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតនោះទេ នៅពេលការព្យួរកិច្ចសន្យាការងារបានធ្វើឡើងដោយស្របតាមនីតិវិធីច្បាប់។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលសម្រាប់ខែមីនា និងខែមេសា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ១១នាក់។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ២ ៖**

- បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលសម្រាប់ខែមីនា និងខែមេសា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ១១នាក់ ដូចក្នុងតារាងបញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទារខាងលើ។

ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹម សុទ្ធី**

ហត្ថលេខា ៖ ------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ទូន ស៊ីផាន់**

ហត្ថលេខា ៖------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------------